ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សេចក្តីប្រកាសព័ត៌មាន

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមជម្រាបជូន លោក លោកស្រី ដែលជាអតិថិជនរបស់ **គម្រោងផ្ទះនិងដីឡូត៍ ឡេង ណាវ៉ាត្រា ជ្រៃ១០០ និងគម្រោងផ្លូវជាតិលេខ ៦អា** ដែលមានទីតាំងស្ថិតនៅភូមិជ្រៃមួយរយ និងភូមិអន្លង់ស្លែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ឱ្យបានជ្រាបថា ក្រសួងនឹងប្រគល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដំណាក់កាលទី៤ ចំនួន **១ ៣៩១បណ្ណ** ជូនអតិថិជនដែលបានបង់ប្រាក់គ្រប់ចំនួន១០០% ដូចមានឈ្មោះក្នុងបញ្ជីជូនភ្ជាប់មកជាមួយ ចាប់ពី**ថ្ងៃទី៩ ដល់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៦** ជារៀងរាល់ម៉ោងធ្វើការ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល ដែលមានអាសយដ្ឋានស្ថិតនៅផ្លូវលេខ២០៩ ភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

សូម លោក លោកស្រី អញ្ជើញមកទទួលបណ្ណកម្មសិទ្ធិ ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. អតិថិជនដែលជាម្ចាស់កម្មសិទ្ធិ ត្រូវអញ្ជើញមកដោយផ្ទាល់។ ក្នុងករណីជាទ្រព្យរួមប្តីប្រពន្ធ សូមអញ្ជើញមកទាំងពីរនាក់ប្តីនិងប្រពន្ធ។

២. សូមភ្ជាប់មកជាមួយនូវឯកសារណាប ដែលអតិថិជនទៅខ្វះ ក្នុងពេលដាក់ពាក្យស្នើសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ កន្លងមក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ជ្រាបជាព័ត៌មាន និងអញ្ជើញមកទទួលបណ្ណកម្មសិទ្ធិឱ្យបានគ្រប់គ្នា។

ថ្ងៃចន្ទ ៧រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៦

ទីតាំងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដី ខេត្តកណ្តាល

អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com